មីនដែលអង្គុយមុខសម្លឹងប្អូនយឺតៗដោយមិននិយាយស្តីមួយខណៈ ក៏ប្រាប់បន្ថែមថា៖

«អធិរាជនេះឈ្មោះថា អង្គមែនរ៉េត៍!»

មេរួព្ទឈ្មោះនេះហើយបុកភឹបក្នុងទ្រូងដូចធ្លាប់ចំណាំ។ ឬមួយជាអធិរាជក្នុងរឿងតំណាលដោយពួកមគ្គុទេសក៍កាលពីព្រឹកនៅប្រាង្គប្រាសាទអតីតរាជវាំងទេ?

នាងខំពន្យល់ បងប្រុសថា៖

«បងមីន ខ្ញុំមិនមែនមមើមមាយព្រោះតែស្តាប់រឿងនិទាននៅអតីតរាជវាំងកាលពីព្រឹកម្សិលទេណ៎ា!»

មីនងក់ក្បាលដោយទឹកមុខបង្ហាញថា គេកំពុងចម្លែកចិត្តមិនដាច់ស្រេច៖

«បងដឹងហើយ! បើឯងមមើម៉េចឯងដឹងថាទ្រង់មានព្រះនេត្រជាត្បូង?»

«ចុះក្រែង ក្រែងបងមីនឯងថា រាជវាំងអធិរាជនិងរឿងនិទានស្នេហ៍ចាស់ ដែលគេនិទានប្រាប់ភ្ញៀវជារឿងមិនពិត សម្រាប់ឃោសនាផ្សព្វផ្សាយលក់សៀវភៅនោះអី?»

មីនមិនរវល់នឹងសំណួរប្អូនស្រីទេ ម្រាមដៃគេដូចជាញាប់ណាស់ក្នុងការ Search ចុះឡើងលើ Internet មាត់រអ៊ូកង្វល់ឆ្ងល់តែឯកឯងថា៖

«ធ្លាប់ឮមកថាស្តេចអង្គនេះមានវិញ្ញាណបរមីជាអង្គសម្រិត! នៅពេលដែលចេញធ្វើសង្គ្រាមទម្រាំបានឈ្នះខ្មាំងសត្រូវម្តងៗ ប្តូររាងកាយរបស់ព្រះអង្គបានក្លាយជាសម្រិតខ្មៅទាំងអស់ ទុកតែភ្នែកមួយគូដែលជាពន្លឺត្បូងខៀវ ទាល់តែពួកគេអាចបំបាញ់ចំព្រះនេត្ររបស់ព្រះអង្គទើបអាចផ្តួលមហិទ្ធិឫទ្ធិនៃទ្រង់បានបាន! ប៉ុន្តែគ្មាននរណាម្នាក់អាចបាញ់ចំភ្នែកទាំងគូនេះទេ ព្រោះភ្នែកនេះ អាចលាក់តួនាទី មិនអាចឲ្យអ្នកណាបាញ់ចំ ឬក៏មិនអាចឲ្យអ្នកណាកំណត់គោលដៅបានដាច់ខាត!»

«ខ្ញុំមិនដែលឃើញរូបទ្រង់ ថែមទាំងមិនដែលដឹងឮរឿងវិញ្ញាណសម្រិតទាំងនេះទេពីមុនមកហេតុអីបានជាខ្ញុំស្រមៃឃើញរូបនេះក្នុងកញ្ចក់!»

មីនងើបមុខមកសម្លឹងប្អូនហើយខ្សឹបៗសួរ៖

«លោកនេះពិតជានៅមានរឿងវិញ្ញាណមែនឬអី? ព្រះរាជាអង្គនេះនៅមានវិញ្ញាណតាមឯងមកឬក៏យ៉ាងណាដែរ?»

ឮបងប្រុសនិយាយពីរឿងនេះកាលណា នាងហាក់ខ្ញុំភ័យខ្លាំងណាស់។ មេរូលូកដៃរកឱបបងប្រុសទៀត ប៉ុន្តែនាងបង្អង់មកវិញព្រោះនឹកឃើញដល់ក្រញាំដៃអនាមិកដ៏ឃើចាប់ដែលបានច្បាមបង្ខំនាងថាមិនអត់ឱបមនុស្សប្រុស។

«មិនបានទេ! បងត្រូវតែរកមនុស្សពិគ្រោះគ្នាអំពីរឿងនេះ!»

មេរូងក់ក្បាលហើយមីនរុញនាងឱ្យថយទៅគេងវិញថែមទាំងបានដណ្ដប់ភួយឱ្យផងចំណែកមេរូក៏ឱបភួយត្រុន។ សម្លឹងជុំវិញខ្លួនចុះឡើង ចិត្តមួយចង់និយាយអ្វីបន្ថែមនឹងមីន ចិត្តមួយទៀតនាងមិនហ៊ានហានិយាយប៉ុន្តែក្នុងខួរក្បាលគិតស្ងាត់ៗថា ៖

«តើអ្នកជាព្រះអង្គនៃរាជវាំងនោះមែនទេ? អ្នកបានតាមខ្ញុំមកហើយនិយាយប្រាប់ខ្ញុំមែនទេ? ខ្ញុំបានយល់សប្តិឬមួយក៏អ្វីៗគ្រប់យ៉ាងជាការពិតដែលអ្នកបានបន្លាចខ្ញុំ? តើធ្វើនេះដើម្បីអ្វីទៅ?»

ពីលើជញ្ជាំង នាឡិកាប៉ោលស្រាប់តែធ្លាក់របូតដែកគោលមកផុយ ទង្គិចគ្នាឆាំងនៅលើកម្រាលឥដ្ឋ ខ្ទាយពាសពេញទៅដោយអំបែង។

ទាំងបងទាំងប្អូនសម្លឹងមុខគ្នាភ្លឹះៗ ខណៈមេរូស្ទុះក្រោកអង្គុយដោយហួសចិត្ត។

«បងមីន ខ្ញុំចង់ចេញពីកន្លែងនេះ ខ្ញុំចង់ទៅផ្ទះម៉ាក់ខ្ញុំ!»

នាងថាទាំងញាប់ញ័រឡើង។

«បងប្រាប់ហើយថាអ៊ីកំពុងតែមក! ព្រលឹមភ្លឺស្រាងៗគាត់មកដល់ហើយ! ម៉ោះ បងនៅនេះទេ កុំភ័យពេក!»

នាងងក់ក្បាលតែយំរហាម ម្ល៉ោះហើយមីនប្រញាប់សុំពេទ្យនាំមេរូចេញពីគ្លីនិកបកត្រឡប់មកសម្រាកនៅផ្ទះវិញ។

ពេលត្រូវបានបងនាំចូលទៅបន្ទប់គេង មេរូសុំគេងនៅលើសាឡុងវិញ មីនក៏សម្រាកក្បែរនោះដែរ។ ថ្ងៃរះច្បាស់ កាលណាមីនចច្រប់ទៅរៀបចំដាំបបរស និងឆុងកាហ្វេយ៉ាងឈ្ងុយនៅបន្ទប់បាយខណៈមេរូទន្ទឹងរងចាំទាំងពោះឃ្លាន គិតថានឹងបានសម្រន់ជាមួយអាហារអស់ទាំងនោះស្រាប់តែចាំយូរពេកក៏លក់ស្លុងទៅទៀត ទាំងមិនដឹងខ្លួនថា ងងុយចាប់ពីពេលណាហេតុអ្វីបានជាងងុយដេកមិនចេះឆ្អែតយ៉ាងនេះ?

នៅក្នុងសុបិននាងបានយល់សប្តិថា ខ្លួនឯងកំពុងតែស្ថិតនៅក្នុងរាជវាំងចាស់ដូចដែលនាងបានឃើញកាលពីព្រឹកម្សិល ធ្វើឱ្យព្រលឹងមេរូតក់ស្លុតឆ្លេឆ្លារកផ្លូវគេចមកភពបច្ចុប្បន្នវិញ ប៉ុន្តែ

ភ្លាមៗនោះនាងសង្កេតឃើញទីឋានដដែលដែលបានទៅទស្សនាតាមមគ្គុទេសក៏ជាមួយបណ្ដាសិស្សបុរាណវិទ្យាផ្សេងៗ ហាក់ប្លែកត្រង់មានការរៀបចំយ៉ាងប្រណីតទៅដោយក្រណាត់សូត្រ និងស្នូរតន្ត្រីបុរាណកំដរយ៉ាងពីរោះរណ្ដំ។

លម្អងនិងស្រទាប់ផ្កាគ្រប់ពណ៌រៀបចំតាំងឡើងជាច្រើនថាស និងពេញថូធំៗ ថែមទាំងមានរោយស្រទាប់ផ្កាអមនៅតាមជណ្ដើរឡើង បង្ហាញថាពិធីអ្វីមួយហាក់កំពុងរៀបចំឡើងយ៉ាងមហោឡារិកតាមលក្ខណៈហិណ្ឌូនៅក្នុងប្រាង្គប្រាសាទនេះតែម្ដង។

មិនយូរប៉ុន្មាន មេរូស្រឡាំងកាំង ព្រោះឃើញស្រីប្រុសមួយគូចេញដំណើរមកអមដោយទាសករស្រីស្នំ និងនាម៉ឺនសព្វមុខឋានៈ។ ទាំងទ្វេអង្គ ត្រូវបានចោមព័ទ្ធអបអរឱ្យយាងលើសំពត់សូត្រក្រាលទទួលវែងអន្លាយ និងរាស្ត្រមន្ត្រីច្រើនរយនាក់ស្រែករំពងសាទរយ៉ាងគគ្រឹកគគ្រេងនៅក្រោមឆ័ត្ររួត ដែលមានប៉ាក់ឱនលម្អទៅដោយត្បូងគ្រប់ពណ៌ភ្លឺច្រាល។

ទាំងទ្វេកាយមានគ្រងមកុដយ៉ាងហ៊ឺហាដូចជាអភិជននាជំនាន់បុរាណសម័យបណ្ដាលមេរូឱ្យនាងភ្ញាក់ក្រញាងពេលដែលខ្លួនខំតាមដានទេពនារីស្លៀកពាក់ពណ៌លឿងវែងនិងមានចេញគ្រាប់ត្បូងមួយនៅចំកណ្ដាលថ្ងាស ស្រាប់តែអង្គនារីនោះងាកមកនាងកាលណាចេញជារូបរាងមេរូខ្លួនឯងទាំងស្រុង។

មេរូភាន់ភាំងស្របពេលអង្គស្ត្រីនោះញញឹមត្រជាក់មកដូចព្រាយបិសាច និងមានត្បូងពណ៌ភ្លើងអគ្គីមួយគ្រាប់ធំនៅចំកណ្ដាលប្រជុំចិញ្ចើម។ ហេតុភេទនេះ បានបណ្ដាលឱ្យនិស្សិតយើងព្រឺក្បាលសំពោងស្រែកយកៗស្លន់ស្លោជើងដៃត្រជាក់ស្រឹប។

ប៉ុន្តែមេរូនៅមិនទាន់បានចាកចេញពីសុបិនដ៏ចម្លែកនេះនៅឡើយដែរ គឺបុរសដែលឈរក្បែរអង្គនារីបានងាកមកតាមដៃគូ ហើយបុរសនោះឯងមានភ្នែកពណ៌ខៀវមួយគូនិងដងខ្លួនជាសម្រឹតខ្មៅ។

«នាងគឺជាភរិយារបស់ខ្ញុំ នាងត្រូវផ្លាស់មករស់នៅជាមួយខ្ញុំ នាងមិនអាចរស់នៅតាមរបៀបនេះឲ្យពួកប្រុសៗប្រមាថមើលងាយនោះទេ!»

ភ្លាមនោះ អង្គនារីបានរលាយបាត់នៅក្នុងការឱបក្រសោបរបស់រាជសម្រឹត ចំណែករាជាក្រោយអង្គនារីរលាយទៅ ទ្រង់បែរជាដើរមួយៗតម្រង់មករកប្រភពដើមនៃរូបមេរូដែលកំពុងតែឈរស្លុតឈឹង។

មកកាន់តែជិត មេរូចង់រត់ តែឆក់ជាប់ជើងដោយវេទមន្ត នាងបានត្រឹមហាមាត់ ស្រែករាលដាលយ៉ាងរន្ធត់ថា «ចេញទៅវិញទៅ! កុំឲ្យសោះ កុំមកជិតខ្ញុំ! ចេញទៅ! ចេញទៅ!»

នាងស្រែកឡុលៗបែបនេះក្នុងចិត្តភ័យត្រជាក់បម្រះរហូតដល់ដឹងខ្លួនឡើងឃើញមីននិងម្ដាយកំពុងតែឈរមាត់ទ្វារសម្លឹងមកខ្លួន។

ទំនងជាម្ដាយទើបមកដល់ឯបងប្រុស ទើបតែចេញទៅបើកទ្វារចំពេលមានការស្រែកកន្ត្រាក់ពីយល់សប្ដិរបស់នាង។

មេរូក្រោកលុបលាងមុខនិងញ៉ាំអាហារពេលព្រឹកដូចជាចត់គ្មានរសជាតិ ប៉ុន្តែនាងបាននិយាយរឿងទាំងអស់ប្រាប់បងជីដូនមួយនិងម្ដាយឥតលាក់លៀមទេ។

ម្ដាយរបស់នាងបានប្រាប់មកវិញថា ដាច់ខាតនាងត្រូវត្រឡប់ទៅស្រុកស្រែវិញសិន ព្រោះគាត់មិនចង់ឲ្យនាងស្នាក់នៅកន្លែងនេះទេ។

«ផ្ទះនេះប្រាកដជាគ្មានអ្នកថែរក្សា បានជាមានព្រលឹងផ្ដេសផ្ដាសតាមមកឆាឆៅបន្តភាគបានអ៊ីចឹងនោះ!»

មេរូឮហើយអង្គុយស្ងៀមពីមុខកែវកាហ្វេ ដូចគ្មានវិញ្ញាណក្នុងខ្លួន។

ម្ដាយនាងចូលបន្ទប់ រៀបចំអុចធូបបួងសួង និងប្រមូលស្លៀកពាក់ខ្លះឲ្យនាង ព្រមទាំងស្រែកហៅមេរូឱ្យទៅស្លៀកពាក់ឱ្យបានត្រឹមត្រូវ និងអាចត្រឡប់ទៅកាន់ស្រុកកំណើតវិញ។

នៅក្នុងបន្ទប់ មេរូកំពុងតែលើកយកសម្លៀកបំពាក់មកពិនិត្យ អ្នកណាម្នាក់ដើរមកពីក្រោយខ្នងនាង។ នាងនិយាយទាំងហត់នឿយ៖

«ម៉ែចេញទៅមុនបានណ៎ា ខ្ញុំផ្លាស់ខោអាវសិន!»

នាងគិតថាអាចជាម្ដាយរៀបចំណោះណុះមិនទាន់រួច ទើបនិយាយបែបដូច្នេះ ស្រាប់តែទ្វារបន្ទប់បិទគ្រឹបយ៉ាងកម្រោលធ្វើឱ្យនាងរបូតចោលសំណុំខោអាវពីដៃ។

ដៃជើងរបស់នាងចាប់ផ្ដើមស្រាល រួចដឹងថាបញ្ចាលែងបាន។

នាងភ័យរកហាមាត់ស្រែកតែស្លុតពេកចេញតែដង្ហើមតឹងៗ។

ដៃទាំងពីរចាប់ផ្ដើមកាច់មកក្រោយដូចជាត្រូវបានអ្នកណាម្នាក់ចងស្លាបសេក។ នាងភ័យខ្លាំងណាស់មេរូចាប់ផ្ដើមដឹងហើយថាច្បាស់ជា មិនមែនមីនក៏មិនមានម្ដាយនាងដែរ។

ក្រញាំមួយទៀតបានច្បាមមកលើកញ្ចឹងក នាងស្រែកភ្លាមថា៖

«កុំធ្វើឱ្យខ្ញុំឈឺ ខ្ញុំឈឺណាស់!»

ដៃនោះមិនស្ដាប់បញ្ជាទេ បានច្របាច់កពីក្រោយនាងរហូតដល់នាងមិនអាចសូម្បីតែហាមាត់និយាយរួច។ គ្រានោះមានសំឡេងមនុស្សប្រុសដដែលលាន់ឡើងក្បែរត្រចៀករបស់នាង៖

«យើងមិនឲ្យនាងទៅណាទេ! ហេតុអីនាងចង់ទៅ?»

ទឹកភ្នែកមេរូស្រក់សស្រាក់ព្រោះនាងភ័យខ្លាំងហើយនិយាយមិនកើត។ ពីក្នុងកញ្ចក់បង្អួចដែលវាតវាត់ចុះឡើងដូចខាងក្រៅមានព្យុះសង្ឃរា នាងឃើញរូបរាងស្ដេចខ្មៅនោះនៅជិតបង្កើយកំពុងតែឈរពីក្រោយកាច់ដៃនាងនិងច្បាមកញ្ចឹងក។

បុរសនេះខ្ពស់ខ្លាំងនិងខ្មៅស្រឹល។ ភ្នែកទ្រង់ភ្លឺដូចត្បូងសម្លឹងមកនាង ដែលនៅយំនិយាយមិនចេញ រួចឱនមកថើបក្បាលនិងសក់មេរូ។

«នាងជាប្រពន្ធយើងហើយ ម្ដេចនាងចង់គេចពីយើង!»

មេរូនឹកឃើញទៅដល់មនុស្សស្រីដែលដើរត្រសងជាមួយទ្រង់លើកម្រាលផ្កានៅក្នុងសុបិនអម្បាញ់មិញ នាងស្រាប់តែហារមាត់សួរបានទាំងយំផងថា «ហេតុអ្វីអ្នកតាមធ្វើបាបខ្ញុំ? តើអ្នកជាស្ដេចនៃអាណាចក្របុរាណបានវិលមកពីប្រាង្គប្រាសាទអតីតរាជវាំងនោះមែនដែរទេ? តើខ្ញុំបានធ្វើអ្វីខុសទៅ!» នាងបញ្ចេញមិនបានច្រើនតាមសំណួររាប់រយក្នុងចិត្តទេ ព្រោះកត្រូវច្បាមជាប់តែ នាងអាចយំស្រែកយំហើយបេះដូងរបស់នាងសោកសៅយ៉ាងខ្លាំង។

ស្ដេចនោះបានទម្លាក់ដៃចោលហិង្សាហើយបីត្រកងនាងដាក់លើគ្រែ។ នៅពេលស្រីនិស្សិតត្រូវស្រឡាំងកាំងស្ដេចខ្មៅដែលគ្មានមាត់បានមានបន្ទូលឡើងថា៖

«កាលពីជាតិមុន នាងស្បថថានឹងទទួលយើងជាស្វាមីគ្រប់ជាតិ!»

«បើមែនម្ដេចខ្ញុំមិនដឹង?!» នាងតវ៉ាពេលភ័យខ្លាចខណៈពេលដែលទ្រង់ឱនចុះមកកាន់តែកៀកឡើងៗចង់ស្រូបយកពន្លឺភ្នែកនារីទាំងសងខាង ទៅគ្រងក្នុងអំណាចភ្នែកទ្រង់។

«ឥឡូវនេះទ្រង់ចង់សម្លាប់ខ្ញុំចោលមែនទេ? ខ្ញុំមិនមែននាងទេ គ្រាន់តែមុខដូចគ្នា នាងមានភ្លើងជារង្វង់នៅក្បែរចិញ្ចើមខ្ញុំគ្មានទេទ្រង់មើលឱ្យច្បាស់ទៅ!»

គ្រាន់តែនាងនិយាយចប់ រាជាខិនមកថើបប្រជុំចិញ្ចើមធ្វើឱ្យតរុណីកើតក្ដៅចំចំណុចស្នាមថើប មានអារម្មណ៍ថាសាច់ប្រេះជាពីរ និងមានក្លិនអគ្គីឆេះចេញមកត្រង់នោះមែន។

សំឡេងមនុស្សប្រុសនិយាយប្រាប់ក្បែរត្រចៀកនាងសារជាថ្មី៖

«យើងយកនាងទៅនៅជាមួយ!»

មេរូគ្រវីក្បាលបដិសេធដាច់អហង្ការ នាងខំប្រឹងធ្វើទន់ខ្លួនប្រុងបិទភ្នែកបន់ឱ្យខ្លួនឯងសន្លប់ឈឹងទៅគេចបានពីសភាពគួរឱ្យភ័យខ្លាចនេះប៉ុន្តែនាងនៅតែដឹងខ្លួនឡើងដដែលព្រោះ រូបកាយខ្មៅបន្តថើបថ្ងាសនាងបន្សល់នូវស្នាមអគ្គីក្ដៅរលាក។ ថើបម្ដងនាងផ្សាម្ដងស្រែកខ្លាំងៗព្រោះឈឺចាប់។

មេរូធ្លាប់បានសិក្សាអំពីសៀវភៅបុរាណជាច្រើនដែរ បើសិននេះគឺជាខ្មោចធម្មតាហេតុអ្វីបានជានៅក្រោមពន្លឺព្រះអាទិត្យអាចចេញមកធ្វើមិនដឹង ហើយមានសកម្មភាពបានសេរី?

ឃើញនាងយំយែកឈឺចាប់ ស្ដេចបានផ្ដុំព្យាបាលស្នាមរបួសទាំងនោះដោយកែវភ្នែកត្រជាក់ល្ហឹមវិញ។ បានធូរស្រាលពីការភ័យខ្លាច នាងមេរូនិយាយឡើងទាំងរើខ្លួនមិនរួច។

«ខ្ញុំត្រូវការដឹងហេតុផលដែលអ្នកកំពុងបំពានខ្ញុំ នេះខុសទម្លាប់របស់អរូបនិងមនុស្ស អ្នកគួរតែកុំសាងបាបជាមួយខ្ញុំអី!»

ស្រមោលខ្មៅតវ៉ាភ្លាមដោយសំឡេងតម្អូញឃឹតៗគួរឱ្យខ្លាចថា៖

«នាងគឺជាភរិយារបស់យើង! យើងទាំងទ្វេបានស្បថថា នឹងរស់នៅជាមួយគ្នា! មុនពេលយើងស្លាប់ នាងបានសន្យាថាគ្រប់ជាតិដោះដូរតែវាសនាជាប្ដីប្រពន្ធជាមួយយើង!»

«ប៉ុន្តែពេលនេះខ្ញុំជាមនុស្សអ្នកបិសាច!»

«យើងមិនមែនជាបិសាចទេ! យើងគ្រាន់តែនៅរង់ចាំជួបប្រពន្ធរបស់យើង! នៅពេលដែលយើងជួបគេហើយយើងនឹងទៅជាមួយគេ លែងនៅវិលវល់ទីនេះ!»

«ខ្ញុំមិនដឹងទេ! ខ្ញុំមិនចងចាំអ្វីទាំងអស់! ហេតុអ្វីបានជាអ្នកមកដាក់រូបខ្ញុំទៅក្នុងរឿងព្រេងមិនពិតទាំងនោះ? អ្នកវង្វេងហើយ! ច្រើនឆ្នាំពេកអ្នកវង្វេងប្រពន្ធហើយ! ភ្ញាក់ខ្លួនឡើង!»

«នៅចង្កេះរបស់នាង មានស្នាមសាក់ដៅឈាម ជាម្រាមដៃដែលប្ដីបានដៅទុកឱ្យចំណាំ!»

មេរូបើកភ្នែកធំៗលែងតវ៉ា។

ស្នាមដៅនេះ នាងសឹងភ្លេចទៅហើយ។ វាប្រៀបបាននឹងស្នាមឈាមដែលនាងខ្លាចហើយម្ដាយនាងនិងចាស់ៗតែងតែរំឭកពីវាថា នាងទំនងជាមានអតីតជាតិមកពីគ្រួសារអភិជនហិណ្ឌូ ឬព្រាហ្មណ៍ដែលនិយមប្រើលោហិតប្ដីមកចាក់ដៅតពូជ។

ពេលនាងនៅភ្លឹកទោរទន់ ព្រះអង្គបានក្លាយមកជារូបរាងបុរសបុរាណមាឌធំ និងមានមុខមាត់គួរឱ្យគយគន់។ បុរសបុរាណញញឹមស្រស់ហាក់ត្រេកអរជាខ្លាំង។

មេរូបានភាន់ភាំងនឹងសម្រស់នេះ។

«ហេតុអ្វីអ្នកត្រូវក្រឡាខ្លួនជាច្រើនយ៉ាង?!»

«យើងបានជាប់នឹងបណ្ដាសាថា រូបពិតនេះ អាចបង្ហាញចេញឡើងតែនៅចំពោះមុខនៃនារីដែលយើងធ្លាប់បានមកជាភរិយា!»

«ចុះហេតុអីបានជាអ្នកមិនក្លាយមកជាមនុស្សមកធ្វើជាប្ដីរបស់ខ្ញុំទៅ?»

«ព្រោះយើងនៅរង់ចាំនាងនៅក្នុងរាជវាំងចាស់!»

«ហេតុអ្វីអ្នកមិនទៅចាប់ជាតិឲ្យបានត្រឹមត្រូវឲ្យក្លាយជាមនុស្សដូចគេឯង?!»

«ព្រោះយើងមិនចង់ភ្លេចអតីតកាល! ប្រសិនយើងទៅចាប់កំណើតថ្មី នៅច្រកផ្លូវនោះគ្រប់គ្នានឹងត្រូវលាងអតីតចោលចេញ! យើងមិនដាច់ចិត្តទេ!»

ស្នូរគោះទ្វារលាន់ឡើង ស្ដេចធ្វើមុខមាំ បញ្ជូនពន្លឺម្យ៉ាងតម្រង់ទៅកាន់ទីនោះហើយក៏ស្ងាត់លែងឮស្នូរគោះ។

អ្នកធ្វើអ្វីពួកគេ?

មេរូងើបមុខសួរ ហើយស្ទុះស្ទាចេញទៅបើកទ្វារសម្លឹងរកមើល។

មិនដឹងយ៉ាងម៉េចបានជានាងធ្វើចលនាបាន?

នៅក្រៅ ឃើញថាមីននិងម្ដាយកំពុងតែដេកលង់លក់ស្កប់លើសាឡុងដូចជាមនុស្សកំពុងសន្លប់។

មេរូបែរមកវិញ ស្ដេចប្រើពន្លឺដដែលរុញទ្វារបិទជិតស្រឹបវិញ។ នៅពេលនាងស្រឡាំងកាំងស្ដេចអង្គនោះបានមកឱបត្រកងបបោសអង្អែលហាក់ប្រាថ្នាចង់រួមមេត្រី។

មេរូចង់លង់ចិត្តនឹងទ្រង់ដែរ តែនាងដឹងខ្លួនមកវិញទាន់ព្រោះពេលដែលងាកទៅសម្លឹងទៅក្នុងកញ្ចក់នាងមិនឃើញរាជាទេ។ នាងយំសោកថា ៖

«អ្នកជាបិសាចពិតណាស់ ហេតុអីអ្នកធ្វើអ៊ីចឹងចំពោះម្ដាយខ្ញុំនិងបងប្រុសខ្ញុំ ពួកគេមិនដឹងរឿងអ្វីទាំងអស់!»

«នាងជាអង្គទិព្វស្ត្រីរបស់យើង ពួកគេគ្មានតម្លៃទេ! បើសិនជានាងចង់ដឹង យើងនឹងទាញអតីតកាលមកឱ្យនាងឃើញ!»

ទ្រង់បានបំបែរមេរូទៅកាន់កញ្ចក់។

«អ្នកជាស្ដេចអធិរាជដែលមានភ្នែកទាំងគូជាត្បូងកណ្ដៀងនោះមែនទេ? តើដំណើររឿងដែលមគ្គុទេសក៍និយាយ ក្មេងស្រីតម្បាញដ៏កម្សត់នោះជាភរិយាអ្នកមែនដែរទេ?!»

ស្ដេចខ្មៅលែងនិយាយអ្វីក៏ចង្អុលឱ្យនាងមើលក្នុងកញ្ចក់....រឿងរ៉ាវអតីតពាន់ឆ្នាំ បានបញ្ចាំងឡើងវិញពីមុខមេរូដូចជាកំពុងមើលភាពយន្ត។

ឆ្នាំ២០៣នៃគ្រឹសករាជ...

ក្រោយប្រកាសជាញជ័យវាយដណ្ដើមបានវាតទីទឹកដីឆ្ពោះទៅទិសខាងជើង សង្គ្រាមដែលមានរយៈពេលដល់ទៅពីរឆ្នាំត្រូវបានបញ្ចប់ ការផ្សព្វផ្សាយសន្តិភាពតាមផ្លូវធ្វើឲ្យមនុស្សជាច្រើននៅរង់ចាំត្រៀបត្រាអបអរទទួលដំណើរព្រះចៅអធិរាជ អង្គមែនរ៉ែត៍ដ៏ក្លាហានវាងវៃនិងខ្លាំងក្លារកអ្វីមកពណ៌នាមិនបាន។

នៅត្រឹមព្រះជន្មដប់ប្រាំបួនវស្សា ដោយសារតែនឿយហត់អាត្មានឹងការទទួលបដិសណ្ឋារកិច្ចរាប់រយគីឡូម៉ែត្រ មិនចេះចប់វេលាជាងដល់ភូមិមួយ ព្រះអង្គបានឃាត់ដំណើរមេទ័ពធំរបស់ខ្លួនឈ្មោះមន្ទ្រាហើយខ្សឹបប្រាប់ថា ចូរឯងក្លែងបន្លំឲ្យមាននរណាម្នាក់បិតនៅលើរទេះសេះរបស់យើងចំណែកយើងវិញនឹងលួចប្រើសម្លៀកបំពាក់ជារាស្ត្រធម្មតាចូលទៅក្នុងភូមិរកសន្តិភាពផ្លូវចិត្ត។

ស្ដេចចង់ ប្រើពេលវេលាស្នាក់អាស្រ័យមួយរាត្រីដោយសុខសាន្តគ្រាណពុំមានការហោកញ្ជ្រៀវបាចផ្កាឬក៏ការថ្វាយបង្គំគាល់នៅតាមផ្លូវ ទ្រង់គ្រាន់តែចង់ដឹងថាយប់ដ៏ស្ងប់ស្ងាត់មួយនៅក្រោយវេលាជាងប្រាំពីររយថ្ងៃនៃការធ្វើសឹកសង្គ្រាម តើនឹងល្អយ៉ាងណាទៅ។

ដោយឃាត់ព្រះអង្គមិនបានមេទ័ពធំមន្ត្រី បានសុំធ្វើដំណើរយាងទៅតាមអមដំណើរនៃព្រះអង្គ ជាគ្រឿងការពារសុវត្ថិភាពជូនដល់មហាអធិរាជ។

មនុស្សជំនិតបានចូលយាត្រាដោយថ្មើរជើងទៅក្នុងភូមិស៊ើបមើលមុន ចំណែកឯព្រះអង្គគង់នៅលើសេះដ៏សាមញ្ញមួយដែលយកពីកូនទាហានមិនឲ្យមានអ្នកណាមើលស្គាល់ថាជាប្រភេទសេះសង្គ្រាមដ៏ល្បីល្បាញក្នុងត្រកូលអធិរាជហ៊ូដាឡើយ។

ពួកគេបានមកដល់ក្នុងភូមិតូចមួយនៅវេលាម៉ោង១យប់ ជាវេលាយប់ស្ងាត់ គ្រប់គ្នាបានពន្លត់ភ្លើងចន្លុះហើយផ្ទះជាច្រើនលាក់ខ្លួនពួនទៅក្នុងស្បៃរាត្រី លើកលែងអីតែមានផ្ទះមួយ ព្រះចៅអធិរាជបានឃើញនូវពន្លឺភ្លើងផ្លុងៗទ្រង់ក៏បានបញ្ជាឱ្យមានទ័ពទៅសុំខ្ទមនោះស្នាក់នៅស្នាក់អាស្រ័យ។

តាមពិតដោយសារតែទ្រង់ឃើញថាគេហដ្ឋានក្បែរនោះដូចជាមានភាពជិតដាមជាត្រកូលស្តុកស្តម្ភគ្រាន់បើជាងគេនាភូមិចុងកាត់មាត់ញកមួយនេះ ឯខ្ទមវិញក៏នៅអែបជាប់របងវា។

មេទ័ពបានសុំឲ្យព្រះអង្គគង់រង់ចាំនៅក្រោមដើមព្រឹក្សាខ្ពស់សាខាមួយ រីខ្លួនក៏រត់ទៅយ៉ាងប្រញាប់ប្រញាល់សាកសួរដំណឹងម្ចាស់ផ្ទះថា តើអធ្យាស្រ័យទទួលជនពនេចរដែរឬទេ។